# របាំត្រុដិនាងម៉េវ

ពាក្យពីរម៉ាត់នៅក្នុងចំណងជើងរបាំត្រុដិនាងម៉េវ គឺ៖ "ត្រុដិ" មានន័យថា "បំបែក" ឬ "កាត់ផ្ដាច់" និង "ម៉េវ" សំដៅទៅលើសត្វឆ្មាឬសូរសត្វឆ្មាយំ។ ខ្មែរយើងមានជំនឿថា សត្វឆ្មាអាចចងពៀរនឹងមនុស្សលោក ជាមួយអ្នកដែលបានប្រព្រឹត្តបាបកម្មអ្វីមួយទៅលើសត្វឆ្មា។ ដូច្នេះហើយបានជាយើងធ្លាប់បានឮចាស់ៗហាមកូនចៅមិនឱ្យធ្វើបាបសត្វឆ្មា រហូតដល់មានពេលខ្លះអ្នកដែលមានការលំបាកអ្វីមួយនៅពេលឈឺមុននឹងស្លាប់ គេថាអ្នកនោះបានធ្វើបាបសត្វឆ្មាពីពេលមុនមក។

នៅក្នុងខេត្តមួយចំនួនមាន ខេត្តសៀមរាបនិងបន្ទាយមានជ័យនារដូវរីងស្ងួតហួតហែង អ្នកស្រុកអ្នកភូមិ ក៏ចាប់ឆ្មាដែលជាធម្មជាតិគឺខ្លាចទឹក មកដាក់នៅក្នុងទ្រុង ហើយក៏ស្រោចឬបាញ់ទឹកទៅលើវា ដោយមានទាំងពិធី តន្ត្រី និងរបាំអមទៅជាមួយផង។ គេធ្វើដូច្នេះដើម្បីឱ្យឆ្មាមានការឈឺចាប់ ដើម្បីឱ្យឆ្មាទៅសូមទេវតាព្រះឥន្ទ្រព្រះព្រហ្មព្រមទាំងវត្ថុស័ក្តិសិទ្ធឱ្យបង្កើតជាភ្លៀងដល់សហគមន៍និងប្រជាពលរដ្ឋ។

ក្នុងការរៀបចំពិធី ជាដំបូងគេពូនធ្វើភ្នំខ្សាច់ធំមួយនៅចំកណ្ដាលទីធ្លាអមដោយភ្នំខ្សាច់បួនតូចៗទៀតព្រមទាំងមានត្រី អណ្ដើក និងក្រពើហែបហែលនៅជុំវិញភ្នំខ្សាច់ទាំងនោះផង។ គេក៏អុជទៀនធូបដោតនៅលើភ្នំខ្សាច់ហើយបួងសួងដល់ទេវតានិងវត្ថុស័ក្តិសិទ្ធសូមឱ្យមានភ្លៀង។

នៅពេលជាមួយគ្នានេះ នៅឯព្រះវិហារនៃវត្តនៅក្នុងភូមិ ព្រះសង្ឃសូត្រធម៌ស្វាធ្យាយប្រោះព្រំទឹកមន្តទៅលើសិល្បករសិល្បការិនីដែលនឹងទៅសម្ដែង។ ក្រោយពីអ្នកសម្ដែងបានចាកចេញពីវត្តហើយ ព្រះសង្ឃក៏នៅតែសូត្រធម៌និងពោលពាក្យថា "ត្រីរ័ស់" រហូតដល់អ្នកសម្ដែងត្រឡប់មកដល់វត្តវិញ។

ក្រុមសិល្បៈលេងភ្លេង ច្រៀង និងរាំពីភូមិមួយទៅភូមិមួយរហូតដល់មានភ្លៀងធ្លាក់ជោគជាំនៅក្នុងស្រែរបស់គេ។ អ្នកសម្ដែងមិនត្រូវបំបែកគ្នាទៅផ្ទះរៀងៗខ្លួនឡើយរហូត

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង

ដល់ព្រះសង្ឃបានសូត្រមន្តបួងសួង និងប្រោះព្រំទឹកមន្តឱ្យពរដល់អ្នកសម្តែងទើបអាចត្រឡប់ទៅផ្ទះវិញបាន។ បើពុំដូច្នោះទេ គេមានជំនឿថាឧបទ្រពចង្រៃអពមង្គលនឹងនៅមានជាប់នៅនឹងខ្លួនរបស់គេ។

តួនិងអ្នកសម្តែងរបាំត្រុដិនាងម៉េវមាន៖ ឆ្មា១ យក្ស២ជាអ្នកសែងឆ្មា អ្នកបាចទឹកម្នាក់ អ្នកជញ្ជាត់ត្រីកាន់ឈ្នាង២នាក់ និងអ្នកកាន់ល្អីឬផ្តិលដើម្បីដាក់ប្រាក់ដែលបានពីពិធីនិងរបាំម្នាក់។ ឯវង់តន្ត្រីមាន៖ អ្នកច្រៀង២នាក់ (ស្រីម្នាក់និងប្រុសម្នាក់) ទ្រ១ ប៉ីប្របុស១ និងស្គរដៃ២។

## ឯកសារពិគ្រោះ

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1998). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.



អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង





អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង